ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jul-2016, 08:55
CMS/CFO: Ly Bunloung

# ការកំណត់និយមន័យនៃអំពើប្រល័យពូជសាសន៍

ថ្ងៃ សុក្រ ទី ២៧ ខែ មករា ឆ្នាំ ២០០៦ Alex Hinton

Raymund Johansen (ប៉ុស្តិ៍, ថ្ងៃទី ១៦ ខែ ធ្នូ) គូសបញ្ជាក់ជាថ្មីអំពីចំណុចសំខាន់ដែលថា អំពើហិង្សាដែលបានកើតឡើង មានភាពគួរឱ្យស្អប់ខ្ពើម និងស័ក្តិសមទទួលការថ្កោលទោសរបស់យើងពេញទំហឹងមិនថាយើងហៅវាថាអ្វី ឬមានការយល់ឃើញផ្នែកអង្គច្បាប់អ្វីខ្លះក្នុងអំឡុងពេលកាត់សេចក្តី។

បន្ទាប់មក Rupert Haw, លើកសំណួរនានា (ប៉ុស្តិ៍ ថ្ងៃទី ១៣ ខែ មករា) អំពីថាតើការសម្លាប់ជាទ្រង់ទ្រាយធំដែលត្រូវបានធ្វើសម្រាប់ "គោលបំណងនយោបាយ" អាចត្រូវបានចាត់ទុកជាអំពើ ប្រល័យពូជសាសន៍ដែរឬយ៉ាងណា (ដូចដែលបង្ហាញដោយអំពើប្រល័យពូជសាសន៍ដែលមានលក្ខណៈមនោគមវិជ្ជានានាដែលបានកើតឡើងក្នុងអំឡុងសតវត្សរ៍ទី ២០ រាប់ពីអំពើប្រល័យពូជសាសន៍ អាមេនី រហូតដល់រវ៉ាន់ដា និងនាពេលបច្ចុប្បន្ននៅដាហ្វួ)។ បើទោះបីជាយើងខ្វែងយោបល់គ្នាលើចំណុចខ្លះក៏ដោយ ក៏សេចក្តីអធិប្បាយរបស់ពួកគាត់ផ្តល់ជាផ្លែផ្កា និងមានលក្ខណៈសមរម្យ។

ផ្ទុយទៅវិញ លិខិតចុងក្រោយបំផុតរបស់ ទួច បូរ៉ា (ប៉ុស្តិ៍, ថ្ងៃទី ១៣ ខែ មករា) លើកឡើងអំពីការបិទបាំងអំពីតួលេខ ការជៀមដាម និងពាក្យគួរឱ្យចង់សើច ដើម្បីលាក់បំបាំងការលើកហេតុផលមិនគ្រប់គ្រាន់ និងការយល់ច្រឡំ។

ក្នុងលិខិតដើមរបស់ខ្ញុំ (ប៉ុស្តិ៍, ថ្ងៃទី ៧ ខែ តុលា) ខ្ញុំបានបញ្ជាក់ថាខ្ញុំយល់ឃើញថាអំពើហិង្សាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ជាអំពើប្រល័យពូជសាសន៍ទាំងក្នុងន័យចង្អៀតនៃអនុសញ្ញា អ.ស.ប និង "ក្នុងន័យទូលាយដែលប្រើប្រាស់ដោយអ្នកស្រាវជ្រាវភាគច្រើនអំពីអំពើប្រល័យពូជសាសន៍ (ដែលរួមបញ្ចូលការប៉ុនប៉ងជាប្រព័ន្ធដើម្បីបំផ្លិចបំផ្លាញក្រុមនយោបាយ និងក្រុមសេដ្ឋកិច្ច ក្នុងចំណោមក្រុមដទៃទៀត)"។

ទួច បូរ៉ា បានឆ្លើយតបថា "អំណះអំណាងនេះមានកំហុសផ្នែកអង្គហេតុ និងអង្គច្បាប់" ហើយថា ខ្ញុំ "មានការភ្នាំភ្នងក្នុងការអះអាងថា (១) ការសម្លាប់ក្រុមនយោបាយ និងក្រុមសេដ្ឋកិច្ចក៏ជាអំពើប្រល័យពូជសាសន៍ផងដែរក្នុង "ន័យទូលាយ" នៃអនុសញ្ញានេះ និង (២) អ្នកស្រាវជ្រាវភាគច្រើនអំពីអំពើប្រល័យពូជសាសន៍មានការឯកភាព" (ប៉ុស្តិ៍, ថ្ងៃទី ៤ ខែ វិច្ឆិកា)។ ទួច បូរ៉ា អានច្រឡំ/យល់ច្រឡំ អំពីផ្នែកទីមួយនៃទឡ្ហីករណ៍របស់ខ្ញុំ ដែលបានលើកឡើងថាករណីនៅកម្ពុជាធានាបាននូវពាក្យអំពើប្រល័យពូជសាសន៍នៅពេលត្រូវបានកំណត់និយមន័យឱ្យបានទូលាយជាងនេះ ដូចបំណងដើមរបស់បុគ្គលដែលបានបង្កើតពាក្យអំ

ពីប្រល័យពូជសាសន៍ (Raphael Lemkin) និងសេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប ដំបូងនៅឆ្នាំ ១៩៤៦ ដែលបានដាក់បញ្ចូល "ក្រុមនយោបាយ និងក្រុមដទៃទៀត"។

នាពេលនេះ ទូច បូរ៉ា ទទួលស្គាល់ទាំងស្រុងអំពីការអានច្រឡំ/ការយល់ច្រឡំរបស់គាត់អំពីចំណុចនេះ និងទទួលស្គាល់ផ្នែកមួយនេះនៃទឡ្ហីករណ៍របស់ខ្ញុំ៖ នៅពេលនេះគាត់កំពុងផ្តោតតែទៅលើនិយមន័យចង្អៀតដែលត្រូវបានប្រកាសឲ្យប្រើក្នុងអនុសញ្ញាហ្សឺណែវ អ.ស.ប ឆ្នាំ ១៩៤៨ ដែលមិនបានដាក់បញ្ចូល "ក្រុមនយោបាយ និងក្រុមដទៃទៀត" សម្រាប់ហេតុផលនយោបាយ។

ហេតុដូច្នេះ យើងនៅសល់តែសំណួរថាតើអំពើប្រល័យពូជសាសន៍បានកើតឡើងក្នុងន័យចង្អៀតនៃអនុសញ្ញា អ.ស.ប ដែរឬយ៉ាងណា។ លិខិតដើមដំបូងរបស់ ទូច បូរ៉ា បានឆ្លើយអំពីបញ្ហានេះក្នុងន័យមិនយល់ស្រប (ប៉ុស្តិ៍, ថ្ងៃទី ៤ ខែ វិច្ឆិកា) ដោយទាញយកឯកសារភស្តុតាងមួយចំនួនតូចមកគាំទ្រអំណះអំណាង របស់គាត់។ បើទោះបីជាខ្ញុំពុំមែនជាមេធាវី ដូចដែល ទូច បូរ៉ា កត់សម្គាល់ ក៏ដោយ ក៏ខ្ញុំអាចបង្ហាញគាត់ថាភស្តុតាងច្រើនជាងនេះជាភស្តុតាងពាក់ព័ន្ធ រួមបញ្ចូលការសិក្សាអំពីប្រជាសាស្ត្រ ការវិភាគកោសលវិច្ច័យ ការធ្វើរបាយការណ៍អង្កេតអំពីការធ្វើផែនទី សក្ខីកម្មរបស់សាក្សីផ្ទាល់ភ្នែក ។ល។ និង។ល។ (ប៉ុស្តិ៍, ថ្ងៃទី ២ ខែ ធ្នូ)។

ក្នុងលិខិតចុងក្រោយបំផុតរបស់គាត់ (ប៉ុស្តិ៍, ថ្ងៃទី ១៣ ខែ មករា) ទូច បូរ៉ា ពុំរិះគន់ខ្លឹមសារនៃទឡ្ហីករណ៍នេះឡើយ ដោយជំនួសមកវិញបានផ្តោតលើប្រភពភស្តុតាងចំនួន ៣ ដែលខ្ញុំលើកឡើង។

ទីមួយ គាត់រិះគន់តួលេខរបស់ អ៊ីសា ឧស្មាន ស្តីពីចំនួនប្រជាជនចាមដែលបានស្លាប់ ដែលខ្ញុំបានលើកយកមកជាសំអាង។ ក្នុងការធ្វើដូច្នេះ គាត់ខ្ចីដោយផ្ទាល់ពីអត្ថបទឆ្នាំ ២០០៣ របស់ Ben Kiernan ក្នុង Critical Asian Studies។ ជាការចម្លែក បន្ទាប់ពីបានប្រើប្រាស់ការរិះគន់របស់ Kiernan អំពី អ៊ីសា ឧស្មាន, ទូច បូរ៉ា មិនទទួលស្គាល់ការងារប្រជាសាស្ត្រលម្អិតរបស់ Kiernan ស្តីពីអំពើប្រល័យពូជសាសន៍ប្រជាជនចាមតាមរយៈការនិយាយថាតួលេខរបស់គាត់ "ខ្ពស់ហួសហេតុ"។ គាត់មិនបង្ហាញ ភស្តុតាងណាមួយដើម្បីគាំទ្រអំណះអំណាងនេះឡើយ។ បើទោះបីជាតួលេខមានភាពខុសគ្នាក្នុងលក្ខខណ្ឌនៃចំនួនជាក់ស្តែងក៏ដោយ ក៏ការសិក្សារបស់ ឧស្មាន និង Kiernan កត់សម្គាល់អំពីចំណុចសំខាន់ដែលថាប្រជាជនចាមហាក់ដូចជាបានស្លាប់ក្នុងអត្រាមួយខ្ពស់ជាងប្រជាជនទូទៅ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ (ការសិក្សារបស់ Kiernan បង្ហាញថាអត្រានៃការស្លាប់របស់ប្រជាជនចាម មានចំនួន ៣៦ ភាគរយ ធៀបជាមួយ២១ភាគរយទូទាំងប្រទេស)។ ដូចដែលខ្ញុំបានគូសបញ្ជាក់ពីដើមដំបូង នេះបង្ហាញថាមានចេតនាប្រ

ល័យពូជសាសន៍មួយដើម្បីបំផ្លាញប្រជាជនចាម បើទោះបីជាភស្តុតាងទាំងនេះត្រូវការការគាំទ្រពីភស្តុតាងដទៃទៀត រួមទាំងការរៀប រាប់របស់សាក្សីផ្ទាល់ភ្នែកក៏ដោយ។

ទីពីរ ទូច បូរ៉ា បញ្ជាក់ថាខ្ញុំមានកំហុសនៅពេលដែលខ្ញុំបាននិយាយថាការវិភាគប្រជាសាស្ត្ររបស់ Ben Kiernan បង្ហាញថាប្រជាជនភាគតិចវៀតណាមចំនួន ២ ម៉ឺននាក់បានស្លាប់ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ។ តាមការពិត គឺ ទូច បូរ៉ា ជាអ្នកខុស៖ Kiernan ប្រើប្រាស់តួលេខនេះនៅលើទំព័រ ៤៥៨ នៃសៀវភៅដែលមានចំណងជើងថា "របបប៉ុល ពត" ដែលតំណាងឲ្យតួលេខនៃការស្លាប់តាមការប៉ាន់ស្មានចុងក្រោយរបស់គាត់សម្រាប់ជនជាតិភាគតិចវៀតណាម (ចន្លោះពី ១ ម៉ឺននាក់ ដល់ ២ ម៉ឺននាក់)។ សូម្បីតែនៅពេលដែលគាត់ប៉ុនប៉ងទាត់ចោលតួលេខរបស់ Kiernan ក៏ ទូច បូរ៉ា ជាថ្មីម្តងទៀត យល់ច្រឡំអំពីចំណុចសំខាន់ដែលថាជនជាតិភាគតិចវៀតណាម ដែលនៅសេសសល់ច្រើនបំផុតហាក់ដូចជាបានស្លាប់ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលជាសញ្ញាបញ្ជាក់អំពីអំពើប្រល័យពូជសាសន៍។

ទីបី ទូច បូរ៉ា បង្ហាញថាខ្ញុំបានកុហក ឬប្រឌិតការសម្ភាន៍មួយដែលក្នុងនោះកម្មាភិបាលមួយរូបដែលបានធ្វើការនៅមន្ទីរឃុំ បានប្រាប់ខ្ញុំថាគាត់បានទទួលលិខិតមួយច្បាប់ដែលបញ្ជាក់ថាជនជាតិភាគតិចវៀតណាម និងចាម ក្នុងចំណោមក្រុមសត្រូវដទៃទៀត គួរត្រូវបាន "បោសសម្អាត"។

សេចក្តីអង្កេតមិនសមរម្យរបស់ ទូច បូរ៉ា ជាថ្មីម្តងទៀតផ្អែកលើការខ្វះការយល់ដឹង។ ទូច បូរ៉ា អះអាងថាប្រសិនបើលិខិតនេះពិតជាមានមែន ការយោងទៅលើលិខិតនេះនឹងមាននៅក្នុងបណ្ណសារ ស២១ ហើយថាប្រព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ ពុំរួមបញ្ចូលឃុំឡើយ។ ប្រសិនបើ ទូច បូរ៉ា ដឹងច្បាស់ អំពីឯកសារបណ្ណសារដែលកំពុងមានអត្ថិភាព គាត់នឹងដឹងថាឯកសារ ស២១ ពុំពេញលេញ ហើយសម្ភារៈឯកសារតិចតួចណាស់ស្តីពីក្បាលម៉ាស៊ីនសន្តិសុខនៃភូមិភាគកណ្តាល/ឧត្តរ ហាក់ដូចជាពុំបានបាត់បង់។

លើសពីនេះ ឃុំគឺជាអង្គភាពរដ្ឋបាលដ៏មានន័យក្នុងភូមិភាគកណ្តាល/ឧត្តរ និងមូលដ្ឋានដទៃទៀត ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទូច បូរ៉ា អាចស្វែងរកការបញ្ជាក់អះអាងអំពីចំណុចនេះ ក្នុងប្រភពស្រាវជ្រាវនានា (សូមមើល ឧទាហរណ៍ Kiernan 1993:13) និងចម្លើយសារភាពនៅទួលស្លែងរបស់កម្មាភិបាលភូមិភាគកណ្តាល/ឧត្តរ ដូចជាចម្លើយរបស់អនុរបស់ កុយ ធួន ឈ្មោះ ស្រេង ។
បន្ទាប់ពីបានលើកឡើងផ្ទួនៗនូវអំណះអំណាងដ៏ខុសឆ្គងរបស់គាត់ដែលថា "ជាការច្បាស់លាស់ គ្មានឡើយមន្ទីរ [ឃុំ]" ទូច បូរ៉ា លើកទឡ្ហីករណ៍ថា "ប្រជាជនចាមពុំស្ថិតក្នុងចំណុចណាមួយជិតការបោស សម្អាត់

ឡើយ””។ នេះជាទឡ្ហីករណ៍មួយដ៏ចម្លែកសម្រាប់មេធាវីដើម្បីធ្វើៈ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ រួមបញ្ចូលការប៉ុនប៉ងបំផ្លាញក្រុមណាមួយ “ទាំងស្រុង ឬមួយផ្នែក”។

ទោះជាយ៉ាងណា ទាក់ទងតំបន់ខេត្តកំពង់ចាមដែលខ្ញុំបានធ្វើការស្រាវជ្រាវ មានភស្តុតាងដែលថានៅកន្លែងខ្លះ ប្រជាជនចាមភាគច្រើន ឬទាំងអស់ត្រូវបានបោសសម្អាត។ របាយការណ៍អង្កេតសម្រាប់តុលាការឆ្នាំ ១៩៧៩ ក៏បង្ហាញអំពីការសម្លាប់រង្គាលជាទូទៅទៅលើប្រជាជនចាមនៅតាមទីកន្លែងនានាដូចជា ស្រុកកំពង់សៀម និងស្រុកកងមាស ។

ជាការពិត ទូច បូរ៉ា នឹងព្យាយាមបង្ខូចប្រភពទិន្នន័យទាំងនេះ។ អាស្រ័យហេតុនេះ ខ្ញុំសូមស្នើយោបល់ថាគាត់ធ្វើអង្កេតដោយខ្លួនឯងនៅតំបន់នេះ។ (មកទល់បច្ចុប្បន្ន គាត់ពុំបានផ្តល់ភស្តុតាងណាមួយដែលថា គាត់ធ្លាប់បានធ្វើការស្រាវជ្រាវបឋមពាក់ព័ន្ធលើបញ្ហានេះឡើយ)។ ខ្ញុំរីករាយប្រាប់គាត់អំពីទិសដៅទៅកាន់ តំបន់ពាក់ព័ន្ធនានានៃភូមិភាគកណ្តាល/ឧត្តរ។ ប្រសិនបើគាត់បានចំណាយពេលវេលាដើម្បីធ្វើការស្រាវជ្រាវបឋមនេះ គាត់នឹងរកឃើញភស្តុតាងដែលថាអំពើប្រល័យពូជសាសន៍ក្នុងន័យចង្អៀតនៃអនុសញ្ញា អ.ស.ប បានកើតឡើង។

ជាចុងក្រោយ ទូច បូរ៉ា អះអាងថា “ការពិតដែលថាចំនួនភាគច្រើននៃមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យមកពីជាតិពន្ធផ្សេងៗ (ចិន/វៀត/ចាម)គាំទ្រការខ្វះចេតនាប្រល័យពូជសាសន៍ទៅលើជាតិពន្ធនានា” (ប៉ុស្តិ៍, ថ្ងៃទី ១៣ ខែ មករា) អំណះអំណាងមួយដែលលើកឡើងម្តងទៀតនូវទឡ្ហីករណ៍មួយដែលគាត់បានធ្វើក្នុងលិខិតមុននេះផ្ញើទៅប៉ុស្តិ៍ (ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៥)។ នេះជាសំអាងហេតុមិនសមស្រប។ ថ្នាក់ដឹកនាំខ្មែរក្រហមបានសម្លាប់កម្មាភិបាលជាន់ខ្ពស់ចំនួន ២ រូប ដែលមានអត្តសញ្ញាណជាតិពន្ធរឹងមាំគឺ ប្រសិទ្ធ (Prasith) និង សួស ម៉ាន (Sos Man)។
មួយវិញទៀត មេដឹកនាំកម្ពុជាប្រជាធិបតេយ្យជាន់ខ្ពស់ភាគច្រើន បានចាត់ទុកខ្លួនឯងជាខ្មែរ និងត្រូវបានកំណត់អត្តសញ្ញាណជាខ្មែរ។ ប្រសិនបើគាត់នៅរស់ ប៉ុល ពត ដែលបានប្រើប្រាស់ឈ្មោះហៅក្រៅថា “ខ្មែរដើម” ប្រាកដជាឆ្ងល់ចំពោះ ទូច បូរ៉ា ដែលបានចាត់ទុកគាត់ជាសមាជិកមួយរូបនៃក្រុមជាតិពន្ធ។

ទូច បូរ៉ា បានខិតខំធ្វើការដើម្បីកម្ពុជា និងស័ក្តិសមទទួលបានការកោតសរសើរលើចំណុចនេះ។ ជាអកុសលលិខិតនាពេលថ្មីៗរបស់គាត់ផ្ញើទៅប៉ុស្តិ៍ ពោរពេញដោយការយល់ច្រឡំ ភាពមិនសមហេតុផល និងកំហុសជាមូលដ្ឋាន។ ខ្ញុំជឿជាក់ថាយើងទាំងពីរសម្លឹងឆ្ពោះទៅការចាប់ផ្តើមនៃតុលាការ ដែលនៅពេលនោះយ៉ាងហោចណាស់អតីតមេដឹកនាំខ្មែរក្រហមមួយក្តាប់នឹងត្រូវបានដាក់ឲ្យទទួលខុសត្រូវ ចំពោះគម្រោងនៃការ

សម្លាប់ជាទ្រង់ទ្រាយធំដែលពួកគាត់បានចូលរួម។ ពេលវេលានឹងបញ្ជាក់ប្រាប់ថាតើពួកគាត់នឹងត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសអំពីអំពើប្រល័យពូជសាសន៍ក្នុងន័យចង្អៀតនៃអនុសញ្ញា អ.ស.ប ដែរឬយ៉ាងណា។

Alex Hinton-សាកលវិទ្យាល័យ Rutgers, New Jersey, ស.រ.អា